# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៣

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៥៧២ សហវ.ប្រក

## ប្រកាស
## ស្តីពី
## ការផ្ទេរឥណទានថវិកា

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣ /០១៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣ / ០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣ / ០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៦៥ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- បានឃើញអនុក្រឹត្យលេខ ៥៦៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរឥណទានថវិកា
- តាមការចាំបាច់ដើម្បីអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

# សម្រេច

**ប្រការ១.–**

ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤ នូវការផ្ទេរឥណទានថវិកាដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម៖

**ក-និយ័តកម្មចេញពី ៩៩ (ចំណាយមិនទាន់បែងចែក)**

ឯកតា លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| | | | **និយ័តកម្មចេញ** | | | | |
| | | | **៩៩ - ចំណាយមិនទាន់បែងចែក** | | | 1 464 032 | |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ(ការប្រាក់) | 230 877 | - | 230 877 | 0 |
| ៦៥ | | | ឧបត្ថម្ភក្រុងស្រុកនិងឃុំ សង្កាត់ | 375 326 | - | 305 056 | 70 270 |
| ៦៥ | | | ចំណាយចរន្តក្នុងការអនុវត្តគម្រោង | 150 000 | - | 20 000 | 130 000 |
| ០៩ | ០៩១ | | ចំណាយត្រៀមបម្រុង | 621 050 | - | 502 250 | 118 800 |
| ១៦ | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 330 924 | - | 330 924 | 0 |
| ២៧ | | | អចលកម្មហិរញ្ញវត្ថុផ្សេងៗ | 74 925 | - | 74 925 | 0 |
| | | | **និយ័តកម្មចូល** | | 1 464 032 | | |
| | | | **១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** | | 1 001 782 | | |
| ៦៦ | | | បន្ទុកហិរញ្ញវត្ថុ(ការប្រាក់) | 0 | 230 877 | - | 230 877 |
| ៦៥ | ៦៥១ | ៦៥១២ | ឧបត្ថម្ភកធនដល់ក្រុងស្រុក | 0 | 67 790 | - | 67 790 |
| ៦៥ | ៦៥១ | ៦៥១៣ | ឧបត្ថម្ភកធនដល់ឃុំ សង្កាត់ | 0 | 237 266 | - | 237 266 |
| ៦៣ | ៧០៩ | | ការសងនិងការបង្វិលវិញ | 0 | 60 000 | - | 60 000 |
| ១៦ | | | ការទូទាត់ប្រាក់ខ្ចីនិងបំណុលប្រហាក់ប្រហែល | 0 | 330 924 | - | 330 924 |
| ២៧ | ២៧១ | | ការឲ្យខ្ចី | 0 | 74 925 | - | 74 925 |
| | | | **១៣- ក្រសួងរ៉ែនិងថាមពល** | | 192 250 | | |
| ៦៥ | ៦៥៥ | ៦៥៥១ | ឧបត្ថម្ភកធនដល់សហគ្រាសសាធារណៈ | 0 | 192 250 | - | 192 250 |
| | | | **២៥- ក្រសួងសាធារណការនិងដឹកជញ្ជូន** | | 250 000 | | |
| ៦១ | ៦១៥ | ៦១៥៣ | ការថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាននិងលូ | 0 | 250 000 | - | 250 000 |
| | | | **២៨-ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ (ថវិកាកម្មវិធី)** | | 20 000 | | |
| ៦៥ | ៦៥៤ | ៦៥៤១ | ចំណាយចរន្តក្នុងការអនុវត្តគម្រោង | 0 | 20 000 | - | 20 000 |

ខ-និយ័តកម្មចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុដើមឆ្នាំ | និយ័តកម្ម | | ឥណទានថ្មីក្រោយនិយ័តកម្ម |
|---|---|---|---|---|---|---|---|
| | | | | | កើន | ថយ | |
| | | | និយ័តកម្មចេញ | | | | |
| | | | ០៥.១ ទីស្ដីការគណៈរដ្ឋមន្ត្រី | | | 500 | |
| ៦៥ | ៦៥២ | | ឧបត្ថម្ភកធនដល់អង្គការសាធារណៈ (អាជ្ញាធរប្រេងកាតជាតិកម្ពុជា) | 41 145 | - | 500 | 40 645 |
| | | | និយ័តកម្មចូល | | | | |
| | | | ១៣- ក្រសួងរ៉ែនិងថាមពល | | 500 | | |
| ៦៥ | ៦៥២ | | ឧបត្ថម្ភកធនដល់អង្គការសាធារណៈ (អាជ្ញាធរប្រេងកាតជាតិកម្ពុជា) | 0 | 500 | - | 500 |

**ប្រការ២.-**

ឥណទានថវិកាដែលបានផ្ទេរក្នុងប្រការ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឲ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរ៉ែនិងថាមពល ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**ប្រការ៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**
- អគ្គនាយកដ្ឋានរតនាគារជាតិ
- អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ